**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

តុលាការខេត្តកំពង់ធំ
<u>សំណុំរឿងព្រហ្មទណ្ឌ</u>
លេខ ២១៤ ចុះថ្ងៃទី ២៦
ខែ មីនា ឆ្នាំ ២០០៤
<u>សាលក្រម</u>
លេខ ៩៨ "គ" ចុះថ្ងៃទី ០៨
ខែ កញ្ញា ឆ្នាំ ២០០៤

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការខេត្តកំពង់ធំ**

បង្កើតឡើងតាមច្បាប់ស្ដីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្ដីនៃរដ្ឋកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ បានបើកសវនាការជាសាធារណៈ នៅសាលជំនុំជំរះតុលាការខេត្តកំពង់ធំ ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៤ ដោយមានសមាសភាពដូចតទៅ :

**<u>ចៅក្រមជំនុំជំរះ</u>**
លោកស្រី [redacted]
**<u>តំណាងអយ្យការ</u>**
លោក [redacted]
**<u>ក្រឡាបញ្ជី</u>**
លោកស្រី [redacted]
**<u>មេធាវីការពារជនរងគ្រោះ</u>**
លោក [redacted]

*សាលក្រមនេះបានចូលស្ថាពរកាលពីថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ២០០៤ រួចហើយដោយគ្មានគូក្ដីណាចូលមកប្ដឹងតាមកំណត់ច្បាប់ ។*
*កំពង់ធំ. ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០០៥*
***ចៅក្រមជំនុំជំរះ***
[redacted]

**<u>ដើម្បីជំនុំជំរះ</u>**

ឈ្មោះ *ស ស* ភេទប្រុស អាយុ ៣៩ឆ្នាំ ជាតិខ្មែរ កើតនៅភូមិក្រយា ឃុំត្រពាំងឫស្សី ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ សាសនាព្រះពុទ្ធ របររកស៊ីកម្មករគាស់គល់ឈើ ប្រពន្ធឈ្មោះ **ជ ស** មានកូន ០៤នាក់ ឪពុកឈ្មោះ **រ ស** (ស) ម្ដាយឈ្មោះ **ឃ ស** (ស) ទោសពីមុន *គ្មាន* ។

<u>ពីបទ *រំលោភសេពសន្ថវៈ*</u> ប្រព្រឹត្តនៅតំបន់បុស្សម្កាក់ ឃុំត្រពាំងឫស្សី ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ កាលពីថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៤ បទល្មើសដែលមានចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៥ ស្ដីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ ។

ដើមបណ្ដឹងរដ្ឋប្បវេណី ឈ្មោះ **ជ ស** ភេទប្រុស អាយុ ៣៨ឆ្នាំ នៅភូមិបុស្សម្កាក់ ឃុំត្រពាំងឫស្សី ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ប្ដឹងថា កាលពីថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៤ ម៉ោង ០៧ព្រឹក ឈ្មោះ **ស ស** បានចាប់កូនស្រីមានអាយុ ១០ឆ្នាំ រំលោភសេពសន្ថវៈរហូតបានសំរេច ។ កន្លងមករំលោភបាន ០៤ដង មកហើយ កូនមិនបានប្រាប់ខ្ញុំទេ ដោយខ្លាចឪពុកចុងឈ្មោះ **ស ស** សំលាប់ចោល ។ សំណូមពរផ្ដន្ទាទោសជនល្មើសទៅតាមច្បាប់ ។

-ដីកាសន្និដ្ឋានស្ថាពរលេខ ៤៨៨ ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០០៤ របស់



Scanned with CamScanner

ព្រះរាជអាជ្ញាអមតុលាការខេត្តកំពង់ធំ ។

-ដីកាបញ្ជូនរឿងទៅជំនុំជំរះលេខ ១១៦០ ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០៤ របស់ចៅក្រមស៊ើបសួរ ។

-ដីកាចាត់តាំងចៅក្រមជំនុំជំរះលេខ ១១៦១ ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០៤ របស់ប្រធានតុលាការខេត្តកំពង់ធំ ។

## ឯរឿងហេតុមានដូចតទៅ

ឈ្មោះ ស ស ជាឪពុកចុងជនរងគ្រោះ ឈ្មោះ ស ម មានអាយុ ១០ឆ្នាំ ពេលទៅចាក់អង្រួង និង រកបង្គោល និង ទៅកន្លែងផ្សេងទៀតតែងចាប់រំលោភ ចំនួន ០៤ដង មកហើយ បានគំរាមអ្នករងគ្រោះមិនឱ្យប្រាប់ម្តាយទេ វានឹងសំលាប់ចោល វារំលោភចុងក្រោយនេះ អ្នករងគ្រោះមានការឈឺចុកចាប់នឹងប្រដាប់ភេទរបស់ខ្លួន មានធ្លាក់ឈាមផង បានប្រាប់ម្តាយតាមដំណើររឿង ក៏សមត្ថកិច្ចធ្វើការឃាត់ខ្លួនតែម្តង ។

## នាពេលសវនាការ

ជនជាប់ចោទឈ្មោះ ស ស បានឆ្លើយបញ្ជាក់ថា ក្នុងខែ មិថុនា ឆ្នាំ ២០០៤ ខ្ញុំបានរំលោភសេពសន្ថវៈ ឈ្មោះ ស ម អាយុ ១០ឆ្នាំ ជាកូនប្រពន្ធខ្ញុំប្តីគេមុន បានរំលោភចំនួន ៤ដង មកហើយរំលោភលើកទី ១ :

១-នាំកូនទៅជញ្ជូនបង្គោលរបងនៅក្រោយផ្ទះ

២-នាំកូនទៅជញ្ជូនបង្គោលរបងនៅក្រោយផ្ទះដែរ

៣-នាំកូនទៅចាក់អង្រួងនៅអូរកន្ទ្រាំង

៤-នាំកូនទៅបេះផ្សិតនៅអូរកន្ទ្រាំង

ខ្ញុំទទួលកំហុសហើយ សូមតុលាការជួយរកយុត្តិធមិឱ្យផង ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ៩ ស បានឆ្លើយបញ្ជាក់ថា ខ្ញុំមានកូនប្តីមុន ០៣នាក់ ដែលមានឈ្មោះ ស ម ភេទស្រី អាយុ ១០ឆ្នាំ ក្រោយមកប្តីបានស្លាប់ ។ នៅចុងឆ្នាំ ២០០៣ ខ្ញុំរៀបការជាមួយឈ្មោះ ស ស ហើយខ្ញុំបានរួមរស់ជាមួយគ្នាមានកូន សំរាលកូនបាន ០១ខែ ប្តីឈ្មោះ ស ស តែងបបួលកូនស្រីឈ្មោះ ស ម ទៅចាក់អង្រួងនៅអូរកន្ទ្រាំង ពេលមកវិញកូនបានប្រាប់ថា ប៉ាធ្វើបាបវាណាស់ខ្ញុំមិនបានចាប់អារម្មណ៍អ៊ីទេ ស្មានតែប្តីខ្ញុំវាយធ្វើបាបខ្ញុំបានប្រាប់កូនឱ្យចេះអត់ធ្មត់ទៅក្រោយមកបាន ០៥ថ្ងៃ ។ ប្តីនាំកូនស្រីឈ្មោះ ស ម ទៅដកផ្សិតនៅអូរកន្ទ្រាំង ពេលមកវិញកូនប្រាប់ថា ប៉ាធ្វើបាបខ្លាំងណាស់ ក៏ខ្ញុំមិនសួរនាំកូនទេ ។ ក្រោយមក ០១អាទិត្យ កូនទៅកាប់បង្គោលរបងជាមួយឈ្មោះ ស ស ពេលមកវិញកូនយំបានប្រាប់ខ្ញុំថា ប៉ាធ្វើបាបវាទៀតហើយ តែខ្ញុំមិនបានចាប់អារម្មណ៍អ្វីទេ ។ ក្រោយ ០៣ថ្ងៃ កូនទៅយកឃ្មុំនៅក្រោយផ្ទះជាមួយប្តីឈ្មោះ ស ស ពេលមកវិញកូនប្រាប់ថា ប៉ាបានចាប់រំលោភវា ០៤ដងហើយ ។ ខ្ញុំបានឃើញកូនមានធ្លាក់ឈាម នឹងហើមប្រដាប់ភេទទៀតផង ។ សូមតុលាការផ្តន្ទាទោសជនល្មើសទៅតាមច្បាប់មិនទាមទារសំណង និង ជំងឺចិត្តអ្វីទេ ។

ជនរងគ្រោះឈ្មោះ ស ម បានឆ្លើយបញ្ជាក់ថា ខ្ញុំត្រូវឪពុកចុងឈ្មោះ ស ស រំលោភ ៤ដងមកហើយ ។ វាមិនឱ្យខ្ញុំប្រាប់ម្តាយទេ បើប្រាប់វាសំលាប់ចោល តែខ្ញុំទ្រាំមិនបាននឹងការឈឺចាប់ប្រដាប់ភេទខ្ញុំ ពេលបត់ជើងឈឺខ្លាំងពេកក៏ខ្ញុំប្រាប់ម្តាយថា ប៉ារំលោភខ្ញុំ ៤ដងមកហើយ ។

របាយការណ៍លេខ ៣០៨ ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៤ របស់នគរបាលប៉ុស្តិ៍ ឃុំត្រពាំងឫស្សី បានបញ្ជាក់ថា កាលពីថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៤ វេលាម៉ោង ៧ នៅតំបន់បុស្សម្កាក់ ក្នុងឃុំត្រពាំងឫស្សី



Scanned with CamScanner

ឪពុកចុងឈ្មោះ ស ស អាយុ ៣៩ឆ្នាំ នៅភូមិស្មោរ ឃុំត្រពាំងឫស្សី បានចាប់កូនចុងឈ្មោះ ស ម ភេទស្រី អាយុ ១០ឆ្នាំ រំលោភសេពសន្ថវៈចំនួន ៤ដងមកហើយ ។

វិញ្ញាបនបត្រពេទ្យបង្អែកខេត្តកំពង់ធំ លេខ ២០៦ ចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០៤ បានបញ្ជាក់ថា បានពិនិត្យអ្នកជំងឺឈ្មោះ ស ម លើផ្លូវភេទទ្វារមាសឈូកស្រាល សន្ទះព្រហ្មចារីយ៍នៅល្អ គ្មានស្លាកស្នាមគួរគត់សំគាល់ ។

តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា ជនល្មើសទទួលស្គាល់កំហុសរបស់ខ្លួនថា បានចាប់រំលោភឈ្មោះ ស ម ភេទស្រី អាយុ ១០ឆ្នាំ ជាកូនចុងរបស់ខ្លួន សូមឱ្យតុលាការបន្ធូរបន្ថយទោសឱ្យផង ។ អយ្យការរក្សាបទចោទដដែល សូមតុលាការសំរេចសេចក្ដីទៅតាមច្បាប់ ។

លោកមេធាវីបានធ្វើសេចក្ដីសន្និដ្ឋានថា ខ្ញុំការពារជនរងគ្រោះជាអនីតិជន ។ សំដីចុងក្រោយជនជាប់ចោទសារភាពថា បានរំលោភលើអ្នករងគ្រោះពិតប្រាកដ ។ ហើយជនរងគ្រោះបានបញ្ជាក់ថា ឪចុងរំលោភខ្លួន ៤ដងមកហើយ ។ សូមតុលាការផ្ដន្ទាទោសជនល្មើសទៅតាមច្បាប់ ។

-បានស្ដាប់ចម្លើយជនជាប់ចោទ·

-បានស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី

-បានស្ដាប់ចម្លើយជនរងគ្រោះ

-បានស្ដាប់សេចក្ដីសន្និដ្ឋានទោសរបស់តំណាងអយ្យការ

-បានស្ដាប់សេចក្ដីសន្និដ្ឋានការពារជនរងគ្រោះរបស់មេធាវី

-បានពិនិត្យសំណុំរឿងចប់សព្វគ្រប់

## តុលាការខេត្តកំពង់ធំ
## យល់ឃើញថា

-ឈ្មោះ ស ស បានចាប់រំលោភជនរងគ្រោះឈ្មោះ ស ម ភេទស្រី អាយុ ១០ឆ្នាំ ដែលជាកូនស្រីដើមរបស់ប្រពន្ធខ្លួនចំនួន ៤ដងមកហើយ ។

-ឈ្មោះ ស ស មានចេតនាចាប់រំលោភលើជនរងគ្រោះ ឈ្មោះ ស ម ដោយបាននិយាយឱ្យទៅកាន់បង្គោលរបងជាមួយខ្លួន និង ទៅកន្លែងផ្សេងៗទៀត ដែលជនល្មើសបានចាប់រំលោភលើជនរងគ្រោះសរុប ៤ដង មកហើយ ។

-ជនរងគ្រោះឈ្មោះ ស ម មានអាយុ ១០ឆ្នាំ ជាអនីតិជនត្រូវឪពុកចុងរំលោភសេពសន្ថវៈចំនួន ៤ដង ហើយទ្រាំការឈឺចុកចាប់របស់ខ្លួនមិនបានក៏ប្រាប់ម្ដាយថា ឪពុកចុងរំលោភ ៤ដងមកហើយនៅឯព្រៃ។

-តំណាងអយ្យការរក្សាបទចោទដដែល សូមតុលាការសំរេចសេចក្ដីទៅតាមច្បាប់ ។

-មេធាវីបានធ្វើសេចក្ដីសន្និដ្ឋានថា សុំឱ្យតុលាការផ្ដន្ទាទោសជនល្មើសទៅតាមច្បាប់ ។

-ដើមបណ្ដឹងរដ្ឋប្បវេណី សុំឱ្យតុលាការផ្ដន្ទាទោសទៅតាមច្បាប់ មិនទាមទារសំណង និង ជំងឺចិត្តអ្វីទេ ។

-ឈ្មោះ ស ស ល្មើសនឹងមាត្រា ៥ ស្ដីពីច្បាប់ស្ថានទម្ងន់ទោស នៃបទឧក្រិដ្ឋ ។

## ហេតុដូច្នេះតុលាការខេត្តកំពង់ធំ
## វិនិច្ឆ័យសេចក្ដី

១-ផ្ដន្ទាទោសឈ្មោះ ស ស ភេទប្រុស អាយុ ៣៩ឆ្នាំ ដាក់ពន្ធនាគារ ១៥ឆ្នាំ ពីបទ : **រំលោភសេពសន្ថវៈ**



Scanned with CamScanner

ប្រព្រឹត្តនៅតំបន់បុស្សម្កាក់ ឃុំត្រពាំងឫស្សី ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ កាលពីថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៤ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៥ ស្តីពីច្បាប់ស្ថានទំងន់ទោស នៃបទឧក្រិដ្ឋ ។ ទោសខាងលើនេះ គិតតាំងពីថ្ងៃចាប់ខ្លួន ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៤ ។

២-សាលក្រមនេះ ប្រកាសជាសាធារណៈចំពោះមុខតួក្តី ទុកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

ចៅក្រមជំនុំជំរះ
ហត្ថលេខានិងត្រា
[redacted]

បានឃើញ
ចៅក្រមជំនុំជំរះតុលាការខេត្តកំពង់ធំ
[redacted]



Scanned with CamScanner